ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៨៦១ ចុះថ្ងៃទី២៩
ខែកញ្ញា ឆ្នាំ២០២១
សាលក្រម
លេខ ២៤០ "ខ" ចុះថ្ងៃទី
១៩ ខែមេសា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូង ខេត្តកំពង់ចាម

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូង ខេត្តកំពង់ចាម ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ ដោយមានសមាសភាពដូចតទៅ :

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូង ខេត្តកំពង់ចាម
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តកំពង់ចាម

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តកំពង់ចាម

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៦១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១-ឈ្មោះ [redacted] វិសនា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគោហេរ ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ទីលំនៅសព្វថ្ងៃភូមិ[redacted]ខេត្តកណ្ដាល, មុខរបរ មិនពិតប្រាកដ, ឪពុកឈ្មោះ [redacted] ឈាន (រ) ម្ដាយឈ្មោះ [redacted] ស្រីមុំ (រ) ប្រពន្ធឈ្មោះ នី មានកូនចំនួន០១នាក់ ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៧ ទោសគ្មានពីមុន គ្មាន ។

**(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៣៣(ឃ)/២១ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)**

**(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ ញាន វិសនា)**

២-ឈ្មោះ [redacted] នោស្យា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ-ឥស្លាម កើតនៅភូ[redacted] ខេត្តកំពង់ឆ្នាំង ទីលំនៅសព្វថ្ងៃភូមិ៣ម ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល, មុខរបរ ជាងដំដែក, ឪពុកឈ្មោះ [redacted] ម៉ាន (រ) ម្ដាយឈ្មោះ [redacted] សារឿន (រ) ប្រពន្ធឈ្មោះ [redacted] ស្រីណា មានកូនចំនួន០១នាក់ ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៨ ទោសគ្មានពីមុន គ្មាន ។

**(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៣៩(ឃ)/២១ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)**

**(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] នោស្យា ហៅ យ៉ា)**

៣-ឈ្មោះ [redacted] ម៉េងហួត ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ កើតនៅ[redacted] ខេត្តកណ្ដាល ទីលំនៅសព្វថ្ងៃភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម, មុខរបរ ចិញ្ចឹមទា, នៅលីវ ឪពុកឈ្មោះ [redacted] ជា (ស) ម្ដាយឈ្មោះ [redacted] សឿន (រ) ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៤ ទោសគ្មានពីមុន គ្មាន ។

**(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៣៧(ឃ)/២១ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)**

**(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ម៉េងហួត)**

៤-ឈ្មោះ [redacted] សុភ័ស ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម, មុខរបរ រើសអេតចាយ, នៅលីវ ឪពុកឈ្មោះ [redacted] ឡេង (ស) ម្ដាយឈ្មោះ វី (រ) ជានីតិជន កម្រិតវប្បធម៌ ថ្នាក់ទី៣ ទោសគ្មានពីមុន គ្មាន ។

**(ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៣៣៥(ឃ)/២១ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១)**

**(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សុភ័ស)**



Scanned with CamScanner

៥-ឈ្មោះ[redacted]កុយ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិកំបោរ ឃុំកូលាប ស្រុកចិត្របុរី ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃភូមិល្វាលើ ឃុំស្ពៅ ស្រុកកងមាស ខេត្តកំពង់ចាម , ប្រពន្ធឈ្មោះ[redacted]ច័ន្ទសុវណ្ណវ័ត្ត មានកូនចំនួន០២នាក់ ជានីតិជន ។ (ក្រៅឃុំ)

(ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨៩២/២១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១)

(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះគា កុយ)

៦-ឈ្មោះ[redacted]ច័ន្ទសុវណ្ណវ័ត្ត ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរលើ ឃុំស្ពៅ ស្រុកកងមាស ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃភូ[redacted] ខេត្តកំពង់ចាម , មុខរបរ កសិករ, ឪពុកឈ្មោះ[redacted]សារី (រ) ម្តាយឈ្មោះ[redacted] សុខលន់ (រ) ប្តីឈ្មោ[redacted]កុយ មានកូនចំនួន០២នាក់ ជានីតិជន ។ (ក្រៅឃុំ)

(ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨៩៣/២១ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១)

(លោកស្រី [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ[redacted]ច័ន្ទសុវណ្ណវ័ត្ត)

ត្រូវជាប់ចោទពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោហេរ ឃុំស្ពៅ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ដំណើររឿងនៃអង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង១៦និង០០នាទី នៅចំណុចផ្លូវលំស្ថិតនៅភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម សមត្ថកិច្ចការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានប្រើវិធានការញុះញង់ ឲ្យមានការលក់ដោយខុសច្បាប់នូវសារធាតុញៀន ដោយប្រើភ្នាក់ងារសម្ងាត់លេខ B-106 ដើម្បីទាក់ទងទិញថ្នាំញៀនពីឈ្មោះ[redacted]សុភ័ស ភេទប្រុស អាយុ២៨ឆ្នាំ ហើយណាត់ភ្នាក់ងារឲ្យទៅយកថ្នាំញៀន នៅផ្លូវលំស្ថិតនៅភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម។ ពេលទៅដល់កន្លែងណាត់ជួបសមត្ថកិច្ចក៏បានឃ្លាំមើលស្រាប់តែឈ្មោះ[redacted] សុភ័ស បានប្រគល់ថ្នាំញៀនឲ្យភ្នាក់ងារ ហើយសមត្ថកិច្ចក៏បានចូលឃាត់ខ្លួនឈ្មោះ[redacted] សុភ័ស ឆែកឆេរ ដកហូតម្សៅក្រាមពណ៌ស សង្ស័យជាថ្នាំញៀន ចំនួន០១កញ្ចប់ ទម្ងន់០,៣១ក្រាម (សូន្យក្បៀសសាមសិបមួយក្រាម) ថ្លឹងទាំងសំបក។ ស្របពេលនោះសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនជនសង្ស័យ ចំនួន០៥នាក់ផ្សេងទៀត ដែលចុះមកដល់ផ្ទះ ឈ្មោះ[redacted]វាសនា ដែលរួមមានទី១.ឈ្មោះ[redacted] ម៉េងហួត ភេទប្រុស អាយុ៣០ឆ្នាំ ទី២.ឈ្មោះ[redacted]ធឿន ភេទប្រុស អាយុ៣៧ឆ្នាំ ទី៣.ឈ្មោះ[redacted]ប៊ុណ្ណា ភេទប្រុស អាយុ២១ឆ្នាំ ទី៤.ឈ្មោះ[redacted]ធារិទ្ធ ភេទប្រុស អាយុ២៥ឆ្នាំ និងទី៥. ឈ្មោះ[redacted] សោភា ភេទប្រុស អាយុ២៧ឆ្នាំ ឆែកឆេរពុំមានថ្នាំញៀនលើខ្លួនរបស់ពួកគេទេ ប៉ុន្តែក្រោយធ្វើតេស្តស្វែងរកសារធាតុញៀន ឃើញលទ្ធផល វិជ្ជមាន មានសារធាតុញៀន ក្នុងខ្លួនរបស់ពួកគេ។ តាមចម្លើយរបស់ឈ្មោះ[redacted]វាសនា បានសារភាពថា រូបគេទិញថ្នាំញៀនពីឈ្មោះ[redacted]នោស្សា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ រស់នៅភូមិពាម ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល។ បន្ទាប់មកសមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនឈ្មោះ[redacted]នោស្សា ហៅ យ៉ា ឆែកឆេរ ដកហូតម្សៅក្រាមពណ៌ស សង្ស័យជាថ្នាំញៀន ចំនួន០៣កញ្ចប់ ទម្ងន់១២៨,២៦ក្រាម (មួយរយម្ភៃប្រាំបីក្បៀសម្ភៃប្រាំមួយ) ក្រាម ថ្លឹងទាំងសំបក ជញ្ជីងថ្លឹងគ្រឿងញៀន ចំនួន០១គ្រឿង និងថង់វេចខ្ចប់ថ្នាំញៀនមួយចំនួន។ ក្រោយពីបានសាកសួរចម្លើយរបស់ឈ្មោះ[redacted]នោស្សា ហៅ យ៉ា បានសារភាពថាថ្នាំញៀនដែលរូបគេលក់គឺទិញពីឈ្មោះ[redacted]កុយ ភេទប្រុស អាយុ៣២ឆ្នាំ និងប្រពន្ធឈ្មោះ[redacted] ច័ន្ទសុវណ្ណវ័ត្ត អាយុ២៧ឆ្នាំ ស្នាក់នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ បន្ទាប់ពីឃាត់ខ្លួនជនសង្ស័យ និងចាប់យកវត្ថុតាងរួចមក សមត្ថកិច្ចក៏បានកសាងសំណុំរឿង បញ្ជូនមកអយ្យការសាលាដំបូងខេត្តកំពង់ចាម ដើម្បីចាត់ការតាមនីតិវិធីច្បាប់។ ក្រោយពីបានស្តាប់ចម្លើយ[redacted] ម៉េងហួច បានសារភាពថា រូបគេជាអ្នកលក់ថ្នាំញៀនឲ្យឈ្មោះ[redacted] វាសនា ចំណែកឈ្មោះ[redacted] ធឿន ឈ្មោះ[redacted]ប៊ុណ្ណា ឈ្មោះ[redacted] ធារិទ្ធ និងឈ្មោះ[redacted] សោភា បានសារភាពថា ពួកគេមិនដែរជួញដូរគ្រឿងញៀនទេ គេចេះតែប្រើប្រាស់ថ្នាំញៀនប៉ុណ្ណោះ ហេតុនេះតំណាងអយ្យការបានសម្រេចឲ្យពួកគេទៅទទួលការព្យាបាលបន្សាបគ្រឿងញៀន ដោយស្ម័គ្រចិត្តរបស់ពួកគេ តាមដីកាសម្រេចលេខ ១៤៦ អ.យ.ខ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៥៤៩ អ.យ.ខ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ របស់ព្រះរាជអាជ្ញាអមសាលាដំបូង ខេត្តកំពង់ចាម ។



Scanned with CamScanner

បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៨១៦ (ឃ)/២១ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូង ខេត្តកំពង់ចាម ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៣ ច.ត ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូង ខេត្តកំពង់ចាម ។

**បានឃើញ** ដីកាសម្រេចដាក់រឿងជម្រះ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងខេត្តកំពង់ចាម ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **វាសនា** បានឆ្លើយបញ្ជាក់ថាៈ កន្លងមកខ្លួនធ្លាប់លក់ថ្នាំញៀនចំនួន០៣ដងមកហើយ ក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២១ ដោយលើកទីមួយ ចំនួន០១កញ្ចប់តូច ក្នុងតម្លៃប្រាំម៉ឺនរៀល នៅភូមិគោហេរ ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល លក់ឲ្យបុរសម្នាក់មិនស្គាល់ឈ្មោះ និងលើកទី០២ ចំនួន០១កញ្ចប់តូច ក្នុងតម្លៃ៣ម៉ឺនរៀល នៅក្នុងភូមិឃុំដដែល និងលើកទី៣ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង៤រសៀល ខ្លួនបានលក់ឲ្យឈ្មោះ ឃ្លូក ចំនួន០១កញ្ចប់តូច ក្នុងតម្លៃ៣ម៉ឺនរៀល នៅចំណុចភូមិព្រែកកុយ ឃុំរកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល ស្រាប់តែពេលនោះសមត្ថកិច្ចឃាត់ខ្លួនតែម្ដង និងឆែកឆេរឃើញថ្នាំញៀនក្នុងខ្លួនចំនួន១១កញ្ចប់តូច ១កញ្ចប់តម្លៃ១០$។ ចំពោះថ្នាំញៀនដែលខ្លួនលក់នោះខ្លួនបានទិញពីឈ្មោះ [redacted] នោស្សា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ទិញម្ដងក្នុងតម្លៃ១៥ម៉ឺនរៀល ទៅ៣០ម៉ឺនរៀល។ ខ្លួនបានទទួលស្គាល់ថា ខ្លួនពិតជាបានលក់ថ្នាំញៀនពិតប្រាកដមែន ខ្លួនសូមសំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **នោស្សា ហៅ យ៉ា** បានឆ្លើយបញ្ជាក់ថាៈ ខ្លួនធ្លាប់លក់ថ្នាំញៀនចំនួន០៣ដងមកហើយ លក់ម្ដងក្នុងតម្លៃ១៥ម៉ឺនរៀល ថ្នាំញៀនដែលខ្លួនលក់នោះ ខ្លួនបានទិញពីឈ្មោះ កុយ ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ពុំស្គាល់ទីលំនៅគាត់ទេ ដោយពេលទិញរាល់ផង ណាត់ប្រគល់នៅចំណុចតាមផ្លូវ ដោយទម្លាក់ចោល ពេលបានរួចទើបខ្លួនវេរលុយទៅឲ្យគាត់ ក្នុងតម្លៃ១៥ម៉ឺនរៀល។ លុះដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៧ល្ងាច មានឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ បានទូរស័ព្ទមកសុំខ្លួនទិញថ្នាំញៀនពីខ្លួនចំនួន១០ម៉ឺនរៀល ពេលនោះខ្លួនបានឆ្លើយប្រាប់ថាមាន ហើយក៏បានណាត់ប្រគល់ថ្នាំញៀន ចំណុចស្ពាន១៩ ភូមិព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល។ ក្រោយពីទូរស័ព្ទរួចខ្លួនក៏បានទៅចំណុចណាត់ជួប ពេលនោះស្រាប់តែមានសមត្ថកិច្ចឃាត់ខ្លួនបានដកហូតចំនួន០១កញ្ចប់ធំ ,លុយចំនួន៥០០$ និងទូរស័ព្ទដៃសាំសុង០១គ្រឿង ,ណូគា ១២៨០ មួយគ្រឿង។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានលក់ថ្នាំញៀន ពិតប្រាកដមែន ខ្លួនសូមសំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **ម៉េងហួត** បានឆ្លើយបញ្ជាក់ថាៈ ខ្លួនចេះប្រើប្រាស់ថ្នាំរយៈពេល០១ឆ្នាំមកហើយ ដោយក្នុងមួយសប្ដាហ៍ ខ្លួនប្រើប្រាស់ចំនួន០១ដងជាមួយឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ ម្ដងក្នុងតម្លៃ២ម៉ឺនរៀល។ ថ្នាំញៀនដែលខ្លួនប្រើប្រាស់ជាមួយឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ គឺខ្លួនដឹងថាឈ្មោះ [redacted] វាសនា ទិញពីឈ្មោះ [redacted] នោស្សា ភេទប្រុស អាយុ២៣ឆ្នាំ នៅភូមិពាម ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល។ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង០៦ល្ងាច ខ្លួនកំពុងតែប្រើប្រាស់ថ្នាំញៀន នៅភូមិគោហេរ ឃុំរកាកោងទី១ ស្រុកមុខកំពុល ខេត្តកណ្ដាល ជាមួយឈ្មោះ [redacted] វាសនា ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនតែម្ដង។ ពេលនោះសមត្ថកិច្ចឃាត់ខ្លួនពុំបានដកហូតអ្វីនោះទេ ខ្លួនពុំធ្លាប់លក់ថ្នាំញៀននោះទេ គឺធ្លាប់តែប្រើប្រាស់ប៉ុណ្ណោះ។ ខ្លួនសូមសំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនបានដឹងពីកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] **សុភ័ស** បានឆ្លើយបញ្ជាក់ថាៈ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល៣ខែមកហើយ ដោយប្រើប្រាស់ជាមួយមិត្តភក្តិរបស់ខ្លួន។ ចំពោះថ្នាំញៀនដែលខ្លួនប្រើប្រាស់គឺទិញពីឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ នៅភូមិគោហេរ ឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្ដាល ចំនួន០៥ដងមកហើយ ក្នុង១ដងតម្លៃ៤ម៉ឺនរៀល។ នៅពេលដែលខ្លួនបានទិញពីឈ្មោះ [redacted] វាសនា រួចហើយខ្លួនប្រើប្រាស់ ខ្លួនឯងខ្លះ និងបន្តទៅឲ្យឈ្មោះ ឃ្លូក ក្នុងតម្លៃ១០$។ លុះដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៣រសៀល មាន



Scanned with CamScanner

ឈ្មោះ យ្លុក ភេទប្រុស អាយុប្រហែល២៣ឆ្នាំ បានទូរស័ព្ទទៅឈ្មោះ [redacted] វាសនា ដើម្បីទិញថ្នាំញៀនម្តងទៀត ក្នុងតម្លៃ១០$ ហើយឈ្មោះ [redacted] វាសនា ក៏បានយកថ្នាំញៀនមកឲ្យខ្លួនចំនួន០១កញ្ចប់តូច។ បន្ទាប់មកខ្លួនក៏បានវិលែកទុកខ្លះ រួចក៏ទូរស័ព្ទទៅឲ្យឈ្មោះ យ្លុក មកយកថ្នាំញៀនពីខ្លួន នៅចំណុចផ្លូវលំស្ថិតនៅភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម។ ក្រោយមកក៏បានទៅដល់កន្លែងណាត់ជួប ស្រាប់តែមានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ពេលដែលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនចំនួន០១កញ្ចប់ លុយចំនួន៣.០០០៛ និងទូរស័ព្ទម៉ាកណូគាស៊ីមពីរមួយគ្រឿង។ ខ្លួនទទួលស្គាល់ថា ខ្លួនពិតជាបានលក់ថ្នាំញៀនពិតប្រាកដមែន តែចំណេញបានតែប្រើប្រាស់ប៉ុណ្ណោះ ខ្លួនសូមសំណូមពរ សុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់រូបខ្លួនផងព្រោះខ្លួនបានដឹងពីកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] កុយ មិនបានឆ្លើយគ្មានចម្លើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទសុវណ្ណារ័ត្ន មិនបានឆ្លើយ គ្មានចម្លើយ ។

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន** ក្រោយពីបានស្តាប់ការសួរដេញដោលរួចមករួចមកឃើញថា ក្នុងសំណុំរឿងព្រហ្មទណ្ឌ ដែលមានជនជាប់ចោទក្នុងឃុំបួននាក់ ឈ្មោះ [redacted] វាសនា,ឈ្មោះ [redacted] នោស្សា ហៅ យ៉ា,ឈ្មោះ [redacted] ម៉េងហួត,ឈ្មោះ [redacted] សុភ័ស និងជនជាប់ចោទក្រៅឃុំពីនាក់ឈ្មោះ [redacted] កុយ,ឈ្មោះ [redacted] ច័ន្ទសុវណ្ណារ័ត្ន យើងសង្កេតឃើញថា ជាលទ្ធផលក្នុងការពិភាក្សាដេញដោលជនជាប់ចោទដែលមានវត្តមានក្នុងសវនាការនេះទាំងបួនរូប គឺសុទ្ធតែបានសារភាពអំពីហេតុជួញដូរនូវសារធាតុញៀន អង្គហេតុនៃការវិលែកជាកញ្ចប់សម្រាប់លក់ អង្គហេតុនៃការកំណត់ដោយបុគ្គលណាម្នាក់ជាអ្នកឈរឈ្មោះលក់គ្រឿងញៀនហើយ ជាអង្គហេតុនៃការដកហូតបទល្មើសជាក់ស្តែងគ្រឿងញៀនទន្ទឹមគ្នានេះផងដែរ បានដកហូតវត្ថុតាងបានទាំងអស់ ដែលបានទិញពីឈ្មោះ [redacted] កុយ,ឈ្មោះ [redacted] ច័ន្ទសុវណ្ណារ័ត្ន គឺបានបញ្ជាក់ថាជាមិត្តភក្តិនឹងគ្នា ផ្អែកតាមអង្គហេតុដែលប្រមូលបានភស្តុតាងដែលបានបញ្ជាក់ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៥៤៩ អ.យ.ខ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ទុកជាបានការដដែលប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

**លោកស្រី** [redacted] ជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] វាសនា,ឈ្មោះ [redacted] នោស្សា ហៅ យ៉ា,ឈ្មោះ [redacted] ម៉េងហួត,ឈ្មោះ [redacted] សុភ័ស,ឈ្មោះ [redacted] កុយ,ឈ្មោះ [redacted] ច័ន្ទសុវណ្ណារ័ត្ន បានធ្វើសេចក្តីសន្និដ្ឋានថា ចំពោះអង្គហេតុចំពោះការទិញឬលក់ប្រភពតែមួយចំពោះឈ្មោះ [redacted] កុយ ឈ្មោះ [redacted] ច័ន្ទ សុវណ្ណារ័ត្ន នាងខ្ញុំសុំធ្វើសេចក្តីសន្និដ្ឋានស្នើសុំឱ្យសម្រាលទោសដល់ជនជាប់ចោទទាំងបួនរូបនេះ ដោយសារពួកគេទាំងបួនរូបនេះបានសារភាពដឹងពីកំហុស ហើយពួកគាត់ពេលពិភាក្សាដេញដោលពួកគាត់បានឆ្លើយថា មានកូន ជាមួយនិងប្រពន្ធ ហើយក្រុមគ្រួសារ ដើម្បីមើលថែ និងគ្រប់គ្រងជីវភាពប្រចាំថ្ងៃរបស់គាត់ផងដែរ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងត្រឹមត្រូវហើយ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចមក

## **សំអាងហេតុ**

-តាមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរបានកំណត់ចោទប្រកាន់លើ ១.ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ២.ឈ្មោះ [redacted] នោស្សា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ-ឥស្លាម ៣.ឈ្មោះ [redacted] ម៉េងហួត ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ៤.ឈ្មោះ [redacted] សុភ័ស ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ៥.ឈ្មោះ [redacted] កុយ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ៦.ឈ្មោះ [redacted] ច័ន្ទសុវណ្ណារ័ត្ន ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

-អង្គហេតុចោទប្រកាន់ខាងលើនេះ បើជនជាប់ចោទ បានប្រព្រឹត្តពិតប្រាកដមែន ហើយត្រូវផ្ទៀង និងធាតុនីត្យានុកូល ជាបទល្មើសព្រហ្មទណ្ឌនោះជនជាប់ចោទ និងត្រូវទទួលការកំណត់ពិរុទ្ធភាព និងត្រូវប្រកាសមូលទោសដល់ជនជាប់ចោទតាមច្បាប់ជាធរមាន ។

-ជនជាប់ចោទជានីតិជនមានស្មារតីធម្មតា និងកាយសម្បទារឹងមាំ ហើយនឹងសមត្ថភាពអាចទទួលខុសត្រូវលើអំពើរបស់ខ្លួនបាន អំពើប្រព្រឹត្តរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិអ្នកដទៃ និងសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម ដែលច្បាប់បានការពារហើយតម្រូវឱ្យផ្តន្ទាទោសតាមច្បាប់ ។

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] នោស្យា ហៅ យ៉ា បានឆ្លើយថាៈ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនចំនួន០១កញ្ចប់ធំ,លុយចំនួន៥០០$ និងទូរស័ព្ទដៃ០២គ្រឿង ម៉ាកសាំសុង០១គ្រឿង និងម៉ាកណូគា ១២៨០ មួយគ្រឿង នៅពេលបញ្ជូនមកតុលាការ តុលាការទទួលបានតែថ្នាំញៀនចំនួន០១កញ្ចប់ធំ និងទូរស័ព្ទដៃ ០២គ្រឿង ម៉ាកសាំសុង០១គ្រឿង និងម៉ាកណូគា១២៨០ មួយគ្រឿង ចំណែកលុយចំនួន៥០០$ តុលាការពុំបានទទួលពីសមត្ថកិច្ចប៉ូលីសឡើយ ។

-តំណាងអយ្យការបានធ្វើសេចក្តីកត់សម្គាល់ដោយរក្សាដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការទុកជាបានការតាមច្បាប់ និងស្នើសុំឲ្យសម្រេចផ្តន្ទាទោសជនជាប់ចោទដោយឆន្ទានុសិទ្ធិ តុលាការកំណត់បានថាតំណាងអយ្យការបានកត់សម្គាល់ត្រឹមត្រូវតាមច្បាប់ហើយ ។

-តាមអង្គហេតុ ទង្វើរបស់ជនជាប់ចោទដែលបានប្រព្រឹត្តកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ បើពិនិត្យធាតុអត្តនោម័ត ជនជាប់ចោទត្រូវតែទទួលការផ្តន្ទាទោសតាមច្បាប់ មិនអាចអនុគ្រោះបានពិតមែន ប៉ុន្តែបើពិនិត្យទង្វើតាមធាតុសត្យានុម័តវិញ ឃើញថាជនជាប់ចោទជាបុគ្គលមានស្ថានភាពគ្រួសារក្រីក្រ ។

-ទទួលការអប់រំមានកម្រិត ជាហេតុនាំឲ្យខ្វះការពិចារណាគ្រប់ជ្រុងជ្រោយ គប្បីតុលាការផ្តល់ស្ថានសម្រាល ។

-ជនជាប់ចោទឈ្មោះ [redacted] នោស្យា ហៅ យ៉ា បានឆ្លើយថាៈ ពេលសមត្ថកិច្ចឃាត់ខ្លួនបានដកហូតថ្នាំញៀនចំនួន០៣កញ្ចប់ ធំ២កញ្ចប់,តូច១កញ្ចប់,លុយចំនួន៥០០$ និងទូរស័ព្ទដៃសាំសុង០១គ្រឿង ,ម៉ាកណូគា១២៨០ មួយគ្រឿង នៅពេលបញ្ជូនមកតុលាការ តុលាការទទួលបានតែថ្នាំញៀនចំនួន០១កញ្ចប់ធំ,និងទូរស័ព្ទដៃសាំសុង០១ មួយគ្រឿង ,ម៉ាកណូគា១២៨០ មួយគ្រឿង ចំណែកលុយចំនួន៥០០$ តុលាការពុំបានទទួលពីសមត្ថកិច្ចប៉ូលីសឡើយ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ១.ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ២.ឈ្មោះ [redacted] នោស្យា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ-ឥស្លាម ៣.ឈ្មោះ [redacted] ម៉េងហួត ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ ៤.ឈ្មោះ [redacted] សុភ័ស ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ៥.ឈ្មោះ [redacted] គុយ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ៦.ឈ្មោះ [redacted] ច័ន្ទសុវណ្ណវ័ត្ត ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោហេរ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះសាលាដំបូងខេត្តកំពង់ចាម

## វិនិច្ឆ័យសេចក្តី

១/ផ្តន្ទាទោសលើៈ

ក-ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ (មានសារពាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) ។

ខ-ឈ្មោះ [redacted] នោស្យា ហៅ យ៉ា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ-ឥស្លាម (មានសារពាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន ១០ឆ្នាំ (ដប់ឆ្នាំ) ។

គ-ឈ្មោះ [redacted] ម៉េងហួត ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ (មានសារពាជាតិដូចខាងលើ)

ឃ-ឈ្មោះ [redacted] សុភ័ស ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ (មានសារពាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ០២ឆ្នាំ (ពីរឆ្នាំ) ។

ង-ឈ្មោះ [redacted] គុយ ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ (មានសារពាជាតិដូចខាងលើ)



Scanned with CamScanner

ច-ឈ្មោះ [redacted] ច័ន្ទសុវណ្ណវ័ត្ត ភេទស្រី អាយុ២៧ឆ្នាំ ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ)

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗចំនួន ១២ឆ្នាំ (ដប់ពីរឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិគោហើរ ឃុំព្រៃកកុយ ស្រុកកងមាស ខេត្តកំពង់ចាម កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/វត្ថុតាងរួមមាន៖

ក.ម្សៅក្រាមពណ៌ស ចំនួន០១កញ្ចប់ ទម្ងន់០,៣១ក្រាម ទាំងសំបក (ឈ្មោះ [redacted] សុភ័ស)

ខ.ម្សៅក្រាមពណ៌ស ចំនួន១១កញ្ចប់ ទម្ងន់៧,២៥ក្រាម ទាំងសំបក (ឈ្មោះ [redacted] វាសនា)

គ.ម្សៅក្រាមពណ៌ស ចំនួន០៣កញ្ចប់ ទម្ងន់ ១២៨,២៥ក្រាម ទាំងសំបក (ឈ្មោះ [redacted] នោស្សា ហៅ យ៉ា)

ត្រូវរឹបអូសបំផ្លាញចោល ។

ឃ.ទូរស័ព្ទដៃចំនួន០៥គ្រឿង៖ ម៉ាកចុចពិលចំនួន០២គ្រឿង, ពណ៌ខៀវ និងពណ៌ខ្មៅ ម៉ាកសាំសុង ០១គ្រឿង ពណ៌ស, ម៉ាករៀលមី០២គ្រឿង ពណ៌ខៀវ និងពណ៌បៃតង ត្រូវរឹបអូសទុកជាប្រយោជន៍រដ្ឋ ។

៣/ ចេញដីកាបញ្ឈប់អនុភាពដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨៩២/២១ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២១ ឈ្មោះ [redacted] កុយ និងដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨៩៣/២១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២១ ឈ្មោះ [redacted] ច័ន្ទសុវណ្ណវ័ត្ត និងសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] កុយ ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] ច័ន្ទសុវណ្ណវ័ត្ត ភេទស្រី អាយុ២៧ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៤/ សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វាសនា, ឈ្មោះ [redacted] នោស្សា ហៅ យ៉ា ,ឈ្មោះ [redacted] ម៉េងហួត,ឈ្មោះ [redacted] សុភ័ស កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] កុយ, ឈ្មោះ [redacted] ច័ន្ទសុវណ្ណវ័ត្ត ។

សម្រេចបើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|

ហត្ថលេខា និងត្រា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៣រោច ខែចេត្រ ឆ្នាំខ្លូវ ចត្វាស័ក ព.ស ២៥៦៥

កំពង់ចាម, ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner